**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.០០២..........ន. គ. ស ស.ជ.ណ

ថ្ងៃព្រហស្បតិ៍ ១០រោចខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០២២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអនុវត្តកាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មកនិយ័តករគណនេយ្យនិងសវនកម្ម សម្រាប់សហគ្រាសដែលមិនរងសវនកម្មឯករាជ្យ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងក្នុងគោលបំណងជំរុញការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពព្រមទាំងធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុចំពោះគ្រប់ភាគីពាក់ព័ន្ធ **និយ័តករគណនេយ្យនិងសវនកម្ម**នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** មានកិត្តិយសសូមជូនដំណឹងដល់ម្ចាស់សហគ្រាសទាំងអស់មេត្តាជ្រាបថា÷សហគ្រាសដែលមិនជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ **មានកាតព្វកិច្ចត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមកនិយ័តករគណនេយ្យនិងសវនកម្ម ចាប់ពីការិយបរិច្ឆេទគណនេយ្យ២០២១ តទៅ។** ក្នុងការអនុវត្តកាតព្វកិច្ចខាងលើ សហគ្រាសត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម÷

១. សហគ្រាសត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយអនុលោមតាមស្តង់ដាគណនេយ្យជាធរមានឱ្យបានរួចរាល់ក្នុងរយៈពេល៣(បី)ខែគិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ និងត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុនោះមក **ន.គ.ស.** មិនឱ្យហួសរយៈពេល ៣ (បី) ខែ និង ១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ។

២. សហគ្រាសត្រូវប្រើប្រព័ន្ធអនឡាញ (E-filing system) របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក និយ័តករគណនេយ្យនិងសវនកម្ម និងត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

**"ការខកខាន ឬ ការយឺតយ៉ាវមិនបានអនុវត្តកាតព្វកិច្ចតាមការកំណត់ខាងលើ សហគ្រាសត្រូវរងទោសទណ្ឌដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម"។**



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ៨៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីនៃ **ន.គ.ស.** តាមរយៈទូរស័ព្ទនិងតេឡេក្រាមលេខ÷០៩៣ ៩១៩ ១៩២/ ០៧០ ៩២៩ ២៣៧/ ០៨៥ ៤៤៤ ៤៨៨។

**និយ័តករគណនេយ្យនិងសវនកម្ម** ជឿជាក់យ៉ាងមុតមាំថា ម្ចាស់សហគ្រាសទាំងអស់នឹងអនុវត្តកាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ និងបានគ្រប់សហគ្រាស។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាសទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីពេលនេះតទៅ។

**អគ្គនាយក**

**ប៊ូ ថារិន**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

Unofficial Translation

KINGDOM OF CAMBODIA
NATION RELIGION KING

Accounting and Auditing Regulator
No: 002 ACAR S.C.N

Date: January 27, 2022

**Letter of Notification**
**on**
The implementation of obligation to submit the Annual Financial Statements to Accounting and Auditing Regulator for the enterprises with no

In accordance with the Royal law NS/RKM/0416/006, dated April 11, 2016 on implementation of the Law on Accounting and Auditing, Sub-Degree No.79 ANKro. BK, dated June 01, 2020 on the Penalties for the Violation of the Law on Accounting and Auditing, in the purpose to effectively implementation of the obligation on Accounting and Auditing and to ensure the transparency, reliability and accountability of Financial Reporting for all related entities, the Accounting and Auditing Regulator of Non-bank Financial Service Authority would like to inform the owner of all the enterprises which are not under the requirement to have the annual financial statements audited shall have submit their annual financial statements to Accounting and Auditing Regulator starting from the accounting period 2021 onwards.

The enterprises shall practice the obligation as below:

1. The enterprises shall prepare annual financial statements in accordance to the Accounting Standard to be ready within 3 months from each year end closing date of accounts and shall submit the financial statements to Accounting and Auditing Regulator (ACAR) no later than 3 months and 15 days from the closing date of each accounting period.
2. The enterprises shall submit the financial statements via Accounting and Auditing Regulator's E-filing system and shall pay the administrative fee for retaining the financial statements in accordance to the Prakas No. 001 ASHor BK, dated January 12, 2022 of Public Service fee of Accounting and Auditing Regulator.

Failure and being late to comply with the obligation determined above, the enterprises shall be penalized in accordance with the Sub-Degree No.79 ANKro. BK, dated June 01, 2020 on the Penalties for the Violation of the Law on Accounting and Auditing.

For more information please contact to Accounting and Auditing Regulator Office by phone and Telegram: 093 919 192/070 929 237/085 444 488.

Accounting and Auditing Regulator strongly believes that all enterprises shall implement the obligation to submit the annual financial statements to Accounting and Auditing Regulator by the deadline.

As the above mentioned, please all the enterprises kindly take note and effectively comply with this notification accordingly.

Director

HE. Bou Tharin